សម្ដេច ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង,**

ទូលព្រះបង្គំ សូមសំដែងនូវអំណរព្រះគុណដ៏ជ្រាលជ្រៅជាទីបំផុត ថ្វាយព្រះករុណាជាអម្ចាស់ជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលបានប្រទាននូវជំនឿជឿជាក់ និងការទុកព្រះទ័យតែងតាំងទូលព្រះបង្គំជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា សំរាប់អាណត្តិថ្មីនេះ ។

ទូលព្រះបង្គំនឹងយកអស់កម្លាំងកាយ និងប្រាជ្ញាក្នុងការរៀបចំ និងដឹកនាំរាជរដ្ឋាភិបាលថ្មីមួយក្នុងស្មារតីនៃការផ្សះផ្សារ បង្រួបបង្រួមជាតិ ដើម្បីស្ថេរភាព សន្តិភាព ការអភិវឌ្ឍន៍ប្រទេស និងសុខុមាលភាពរបស់ប្រជារាស្ត្រជាទីស្នេហានៃយើង ។

សូមព្រះករុណាជាអម្ចាស់ ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំ ៕

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

**ហ៊ុន សែន**